នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Nov-2012, 14:56
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង សុំឲ្យបញ្ជាក់ឯកសារបន្ថែមដែលពាក់ព័ន្ធនឹងវគ្គសវនាការស្ដីពីការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ និងញត្តិស្នើសុំកំណត់កាលវិភាគសម្រាប់សវនាការដេញដោលលើឯកសារ**

---

| <u>អ្នកដាក់ឯកសារ:</u> | <u>អ្នកទទួលឯកសារ:</u> | <u>ចម្លងជូន:</u> |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | |
| | ចៅក្រម យូ ឧត្តរា | មេធាវីការពារក្ដីជនជាប់ចោទ: |
| | | លោក សុន អរុណ |

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីៈ** | លោក Michiel PESTMAN |
| | លោក Victor Koppe |
| ពេជ អង្គ | លោក អាង ឧត្តម |
| Elisabeth SIMONNEAU FORT | លោក Michael G.KARNAVAS |
| | លោក គង់ សំអុន |
| | លោក Arthur VERCKEN |
| | លោក Jacques VERGÈS |
| | Anta GUISSÉ |

# ចម្លើយតប

១- កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សវនាការដេញដោលលើឯកសារនាពេលខាងមុខ" និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង សុំឱ្យកំណត់អត្តសញ្ញាណនៃពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់ក្នុងសវនាការ (ឯកសារលេខE208/4) ហើយនិងសំណើរបស់មេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន សុំឱ្យកែតម្រូវឡើងវិញលើបញ្ជីភ័ស្តុតាងគាំទ្របន្ថែម (ឯកសារលេខ E223) [ពីពេលនេះតទៅហៅថា សេចក្តីសម្រេច][1] ក្រោមចំណងជើងថា "*ក)អំណះអំណាងតទល់ទាក់ទងទៅនឹងឯកសារដែលនៅសេសសល់ទាំងអស់នៅក្នុងសវនាការ*" ទីមួយ អង្គជំនុំជម្រះសាលាដំបូងបានស្នើទៅភាគីនានាឱ្យបញ្ជាក់ថា តើមានឯកសារបន្ថែមណាខ្លះដែលមកពីក្នុងបញ្ជីឯកសារដើមរបស់ខ្លួន (ចុះខែមេសា ឆ្នាំ២០១១) ដែលខ្លួនស្វែងរកដាក់ទាក់ទងទៅនឹងវគ្គសវនាការស្តីពីការជម្លៀសប្រជាជនចេញ និងទួលពោធិ៍ជ្រៃ មិនឱ្យហួសពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២។ ទីពីរ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អំពីបំណងរបស់ខ្លួន ក្នុងការបើកសវនាការទាក់ទងទៅនឹងឯកសារដែលនៅសេសសល់ទាំងអស់ដែលភាគីនានាបានស្វែងរក នៅក្នុងសំណុំរឿងលេខ០០២/០១ ប៉ុន្តែមិនទាន់បានធ្វើការដេញដោលតទល់គ្នានៅឡើយ។ នៅក្នុងអនុស្សរណៈរបស់ខ្លួនដែលមានចំណង ជើងថា "*សេចក្តីណែនាំដល់ភាគីនានាបន្ទាប់ពីសវនាការថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២*" អង្គជំនុំជម្រះបានឱ្យដឹងថាបន្ទាប់ពីសវនាការកាលពីខែតុលា ឆ្នាំ២០១២ ស្តីពីការបង្ហាញឯកសារទាក់ទងអំពីរចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យ (និងការប្រាស្រ័យទាក់ទង)មក "ការធ្វើសវនាការបន្ថែមទៀតស្តីពីការបង្ហាញឯកសារ និងត្រូវបានកំណត់ការវិភាគនៅក្នុងពេលឆាប់ៗនេះ"[2]។

[1] ឯកសារលេខ **E223/2**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខនៃដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារលេខE208/4) និងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ (ឯកសារលេខ E223)",ចុះថ្ងៃទី១៩ តុលា ២០១២។

[2] ឯកសារលេខ E233 អនុស្សរណៈដែលមានចំណងជើងថា "សេចក្តីណែនាំទៅភាគីក្រោយសវនាការថ្ងៃទី ២១ កញ្ញា ២០១២" ចុះថ្ងៃទី២៤ កញ្ញា ២០១២។

២- សហព្រះរាជអាជ្ញានឹងដោះស្រាយបញ្ហានីមួយៗក្នុងចំណោមបញ្ហាទាំងបីនេះម្តងមួយៗ ដើម្បីជួយអង្គជំនុំជម្រះសាលាដំបូង ក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីកំណត់កាលវិភាគសវនាការឱ្យបានប្រកបដោយប្រសិទ្ធភាព និងសមត្ថភាពស្តីពីភាពអាចទទួលយកបាននៃឯកសារ ដែលនៅសេសសល់ និងសវនាការស្តីពីតម្លៃភស្តុតាងនៃឯកសារដែលបានជ្រើសរើសដែលពាក់ព័ន្ធនឹងបញ្ហាផ្សេងៗគ្នានៅក្នុងសវនាការនេះ។

## សវនាការស្តីពីការទទួលស្គាល់ឯកសារ

៣- ដើម្បីបញ្ជាក់បំភ្លឺដល់អង្គជំនុំជម្រះសាលាដំបូង អំពីឯកសារទាំងឡាយដែលនៅសេសសល់ដែលទាក់ទងនឹងសវនាការដំណាក់កាលដំបូងដែលនៅតែតម្រូវឱ្យដាក់ដើម្បីធ្វើការដេញដោលតទល់គ្នាដដែល ដូចដែលបានលើកយោងនៅក្នុងកថាខណ្ឌទី៥នៃសេចក្តីសម្រេច។ សហព្រះរាជអាជ្ញាបានពិនិត្យឡើងវិញលើឯកសារនានាដែលភាគីទាំងអស់បានបញ្ជូនមក នៅក្នុងពេលដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនកាលពីខែកក្កដា ឆ្នាំ២០១១។ ឆ្លងតាមការពិនិត្យឡើងវិញនេះ បានធ្វើឱ្យជឿថាមានឯកសារនៅសេសសល់តែ៤៨ប៉ុណ្ណោះដែលមកគ្រប់ភាគីទាំងអស់រួមគ្នា ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ នៅក្នុង **ឧបសម្ព័ន្ធទី១** ដែលភ្ជាប់ជាមួយ គឺជាបញ្ជីឯកសារទាំង៤៨នេះ ដែលក្នុងនោះមានពីរដែលត្រូវបានលើកយោងនៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញ (ដំណាក់កាលទី២ និងទី២) និងទួលពោធិ៍ជ្រៃ ហើយនិងឯកសារចំនួន៤៦ ដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងដោយអង្គជំនុំជម្រះសាលាដំបូង អាស្រ័យទៅតាមសេចក្តីសម្រេចថ្មី (ឯកសារលេខE190) ឬមួយក៏ឯកសារទាំងនោះត្រូវដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយភាគីនានាបន្ទាប់ពីខែកក្កដា ឆ្នាំ២០១១មក ដោយអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង។ ក្នុងចំណោមឯកសារ៤៦នេះ មានឯកសារ៦ត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីដោយសហព្រះរាជអាជ្ញា, ឯកសារ៣ទៀតដាក់បញ្ចូលដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និង៤ដោយមេធាវីការពារក្តី អៀង សារី, ២២ ដោយមេធាវីការពារក្តី ខៀវ សំផន និងឯកសារ១១ទៀតដោយមេធាវីការពារក្តី នួន ជា។

៤- ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង ចំនួនឯកសារដែលនៅក្នុងសំណើដើមដែលបានស្នើសុំដោយភាគីពាក់ព័ន្ធ និងដោយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលពាក់ព័ន្ធ មានបញ្ជាក់នៅ

ក្នុងជួរបន្ទាត់បញ្ឈរ"ប្រភព"។ ឯកសារដែលនៅសេសសល់ចំនួន៤៨ <u>មិនមាន</u>ឯកសារណាមួយនៅក្នុងនោះដែលត្រូវបានគេដាក់ដើម្បីធ្វើការតទល់គ្នារួចហើយ ឬក៏ជាប្រភេទឯកសារដែលបានដាក់តទល់នៅក្នុងសវនាការដាច់ដោយឡែកនោះទេ ដូចជាកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស ចម្លើយសាក្សីផ្សេងៗទៀត ពាក្យបណ្តឹង ឬពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលបានបញ្ជាក់ដោយអង្គជំនុំជម្រះ។

៥- ដោយសារសារតែចំនួនឯកសារដែលនៅសេសសល់មានចំនួនកំណត់នោះ សហព្រះរាជអាជ្ញាផ្តល់ជាអនុសាសន៍ឲ្យធ្វើការកំណត់កាលវិភាគដើម្បីបើកសវនាការមួយនៅសប្តាហ៍ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ ស្តីពីភាពអាចទទួលយកបាន ដើម្បីពិភាក្សាលើឯកសារទាំង៤៨នោះរួមគ្នាជាមួយនឹងឯកសារបន្ថែម ដែលភាគីនីមួយៗនឹងធ្វើការកំណត់អត្តសញ្ញាណអោយបានរួចរាល់ នៅត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០១២ ខាងមុខនេះ ដោយយកចេញមកពីបញ្ជីឯកសារដើមរបស់ពួកគេដែលបានដាក់ជូន កាលពីខែមេសា ឆ្នាំ២០១១ ដែលពាក់ព័ន្ធនឹងវគ្គសវនាការស្តីពីការជម្លៀសប្រជាជន (នៅដំណាក់កាលទី១ និងទី២) និងទួលពោធិ៍ជ្រៃ។ សហព្រះរាជអាជ្ញាស្នើយោបល់ថា សម្រាប់ការធ្វើសវនាការនេះគឺត្រូវការរយៈពេលតែមួយថ្ងៃប៉ុណ្ណោះ។

៦- ចំណែកឯកសារបន្ថែមចំណួន៩៤ លើសពីនេះទៀត ដែលសហព្រះរាជអាជ្ញាបានស្វែងរកសុំឲ្យដាក់ជូនអង្គជំនុំជម្រះ ដែលទាក់ទងទៅនឹងការជម្លៀសប្រជាជនដំណាក់កាលទី១ និងទី២ និងទួលពោធិ៍ជ្រៃចំនួននោះ គឺមាននៅក្នុង**ឧបសម្ព័ន្ធ២ក**(៨៨ឯកសារ), **ឧបសម្ព័ន្ធ២ខ**(២ឯកសារ) និង**ឧបសម្ព័ន្ធ២គ**(៤ឯកសារ)នីមួយៗដែលជូនភ្ជាប់មកជាមួយនេះ។ ឧបសម្ព័ន្ធទាំងបីដែលមានទម្រង់ជាតារាងមានបញ្ជាក់សម្រាប់ឯកសារនីមួយៗ អំពីលេខឯកសារ ប្រភេទអ្នកនិពន្ធឯកសារ លេខERN តាមភាសានីមួយៗ ពិពណ៌នា និងចំណុចដែលពាក់ពន្ធនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ដីកាដំណោះស្រាយ) និងលេខយោងរបស់ការិយាល័យសហព្រះរាជអាជ្ញា(កសព) ដែលនៅក្នុងបញ្ជីឯកសារ អនុលោមតាមវិធាន៨០(៣) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ (ឯកសារលេខ E9/31)។

៧- ឯកសារចំនួន៩៤ទាំងនោះ <u>មិនមាន</u> នៅក្នុងកំណត់ហេតុស្តាប់ចម្លើយណាមួយរបស់ កសចស, កំណត់ហេតុស្តាប់ចម្លើយសាក្សីដទៃទៀត, បណ្តឹង ឬពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ ដើម្បីកុំឲ្យមានការត្រួតគ្នាជាមួយនឹងសំណើពីមុនរបស់ កសព លេខ E208, E208/2 និង E96/8។

## សវនាការស្តីពីការបង្ហាញឯកសារ

៨- នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង លេខE233 អង្គជំនុំជម្រះបានសម្រេចធ្វើសវនាការបន្ថែមទៀតអំពីការបង្ហាញឯកសារ ក្រៅពីឯកសារដែលបានបង្ហាញនៅក្នុងសវនាការថ្ងៃទី១០, ទី១៨ និងទី១៩ ខែតុលា ឆ្នាំ២០១២ ដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល និងការប្រាស្រ័យទាក់ទង។

៩- ដោយស្របទៅនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការធ្វើសវនាការលើការបង្ហាញឯកសារដែលទាក់ទងនឹងបញ្ហាផ្សេងៗក្នុងសំណុំរឿង០០២/០១ សហព្រះរាជអាជ្ញាស្នើថាសវនាការ៥បន្ថែមទៀត នឹងអនុញ្ញាតឲ្យភាគីនានាមានលទ្ធភាពអាចធ្វើការបង្ហាញពីឯកសារសំខាន់ៗ ឬឯកសារដាក់បង្ហាញផ្សេងៗ ដែលទាក់ទងទៅនឹងបញ្ហាសវនាការដែលនៅសេសសល់នានា ខណៈដែលសវនាការគ្មានការបង្ហាញឯកសារត្រូវបានគេធ្វើឡើង។ តទៅខាងក្រោមនេះ សហព្រះរាជអាជ្ញាបញ្ជាក់ថាកាលបរិច្ឆេទសវនាការ និងរយៈពេលដែលគ្រោងសម្រាប់ធ្វើសវនាការ ដែលសហព្រះរាជអាជ្ញាជឿជាក់ថានឹងផ្តល់ដល់ភាគីនានានូវពេលវេលា សម្រាប់ធ្វើការការត្រៀមរៀបចំ និងការបង្ហាញបានយ៉ាងគ្រប់គ្រាន់ ដើម្បីធ្វើការបង្ហាញឲ្យមានប្រសិទ្ធភាពនូវទិដ្ឋភាពសំខាន់ៗនៃករណីរបស់ពួកគេបាន។ សហព្រះរាជអាជ្ញាសេចក្តីសន្និដ្ឋានបន្ថែមទៀតថា តាមរយៈការធ្វើសវនាការដោយមានចន្លោះពេលទៀងទាត់ នៅពេញមួយត្រីមាសដំបូងនៃឆ្នាំក្រោយនេះ មុខជានឹងមានការថ្លឹងថ្លែងល្អប្រសើរមួយរវាងការផ្តល់សក្ខីកម្មដោយសាក្សី និងសវនាការលើឯកសារផងដែរដែលសម្រាប់ឲ្យសាធារណជនបានស្តាប់ពីប្រភពផ្សេងៗគ្នានៃភ័ស្តុតាងនៅក្នុងសំណុំរឿងនេះ ទៅតាមរបៀបមួយដែលប្រកបទៅដោយការថ្លឹងថ្លែង និងដែលមានលក្ខណៈទៀងទាត់។

## ក. កាលវិភាគស្នើសម្រាប់ធ្វើសវនាការស្ដីពីការទទួល និងការបង្ហាញឯកសារ

១០- ដោយហេតុនេះ សហព្រះរាជអាជ្ញាដាក់ស្នើជូននូវកាលវិភាគទាក់ទងទៅនឹងសវនាការស្ដីពីការទទួល និងការបង្ហាញឯកសារ ដែលជាផ្នែកនៅសេសសល់នៅក្នុងសំណុំរឿងនេះដូចតទៅ៖

១) សប្ដាហ៍នៃថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣: <u>សវនាការស្ដីពីការទទួលឯកសារ៖</u> [១]ឯកសារនៅសេសសល់ចំនួន៤៨នៅក្នុង**ឧសម្ពន្ធ ១** និង[២]បន្ថែមទៅលើការជម្លៀសដោយបង្ខំដំណាក់កាលទី១ និងទី២ និងឯកសារទួលពោធិ៍ជ្រៃ..................[១ថ្ងៃ]

២) សប្ដាហ៍នៃថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៣: <u>សវនាការស្ដីពីការបង្ហាញឯកសារ៖</u> ការជម្លៀសប្រជាជនដោយបង្ខំ ដំណាក់កាលទី១.......................... ....[១ថ្ងៃ]

៣) សប្ដាហ៍នៃថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣: <u>សវនាការស្ដីពីការបង្ហាញឯកសារ៖</u> ការជម្លៀសប្រជាជនដោយបង្ខំ ដំណាក់កាលទី២ និងទួលពោធិ៍ជ្រៃ....... [១ថ្ងៃ]

៤) សប្ដាហ៍នៃថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣: <u>សវនាការស្ដីពីការបង្ហាញឯកសារ៖រចនាសម្ព័ន្ធឃោសនា</u>[១ថ្ងៃ]

៥) សប្ដាហ៍នៃថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣: <u>សវនាការស្ដីពីការបង្ហាញឯកសារ៖</u> គោលនយោបាយនៃសហឧក្រិដ្ឋកម្មរួម (JCE)............................. [១ថ្ងៃ]

៦) សប្ដាហ៍នៃថ្ងៃទី១ ខែមេសា ឆ្នាំ២០១៣: <u>សវនាការស្ដីពីការបង្ហាញឯកសារ៖</u> តួនាទីផ្សេងៗរបស់ជនជាប់ចោទ..................................................[២ថ្ងៃ]

៧) សប្ដាហ៍នៃថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៣: <u>សវនាការស្ដីពីការទទួលឯកសារ៖</u> កំណត់ហេតុស្ដាប់ចម្លើយសាក្សី បណ្ដឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី................................................[២ថ្ងៃ]

១១- តាមរយៈការរៀបចំកាលវិភាគសវនាការឲ្យបានល្អប្រសើរជាងមុន ទៅតាមរបៀបមួយដែលមានលក្ខណៈទូលំទូលាយនេះ សហព្រះរាជអាជ្ញាសេចក្ដីសន្និដ្ឋានថា កាលវិភាគនេះនឹងជួយដល់ភាគីបានយ៉ាងច្រើននៅក្នុងការបែងចែកពេលវេលារបស់ខ្លួនក្នុងពេលនេះ និងនៅក្នុងរយៈពេលចំនួន៦ខែខាងមុខ សម្រាប់ធ្វើការរៀបចំឯកសារ និងស្ដាប់សក្ខីកម្មរបស់សាក្សី តាមរបៀបមួយប្រសើរបំផុត។ កាណ៏នេះអាចធានាបានថា សវនាការនេះមុខជានឹងមានប្រសិទ្ធភាព និងសមត្ថភាព តាមដែលអាចធ្វើទៅបាន។

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសស*

## ដំណោះស្រាយដែលបានស្នើសុំ

១២- សហព្រះរាជអាជ្ញាស្នើដោយគោរពចំពោះអង្គជំនុំជម្រះឲ្យ៖

១) បញ្ជាក់ថាឯកសារចំនួន៤៨ដែលមានចុះបញ្ជីនៅក្នុង**ឧបសម្ព័ន្ធ ១** គឺជាឯកសារដែលនៅសេសសល់ ដែលចាំបាច់ត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

២) រៀបចំពេលធ្វើសវនាការស្ដីពីការទទួលយកឯកសារ ដើម្បីដេញដោលឯកសារដែលនៅសេសសល់ចំនួន៤៨ នៅក្នុង**ឧបសម្ពន្ធ ១** ជាមួយនឹងឯកសារបន្ថែមដែលភាគីនិមួយៗនឹងកំណត់អត្តសញ្ញាណត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០១២ ចេញពីបញ្ជីឯកសារដើមកាលពីខែមេសា ឆ្នាំ២០១១ ដែលទាក់ទងទៅនឹងការជម្លៀសប្រជាជន(ដំណាក់កាលទី១ និងទី២) ព្រមទាំងវគ្គសវនាការពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ រួមមានឯកសារដែលចុះក្នុង**ឧបសម្ពន្ធ២ (ក) (ខ) (គ)** ដូចជូនភ្ជាប់មកជាមួយ។

៣) កំណត់កាលបរិច្ឆេទធ្វើសវនាការពាក់ព័ន្ធនឹងការទទួលយក និងការបង្ហាញឯកសារ តាមលំដាប់លំដោយ ការទុកចន្លោះពេល និងរយៈពេលដូចដែលបានផ្ដល់ជាអនុសាសន៍ នៅក្នុងកថាខណ្ឌទី១០នៃញត្តិនេះ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ | **លោក យ៉េត ចរិយា** សហព្រះរាជអាជ្ញា | | |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | |